# សារៈសំខាន់នៃដំណាំរួមផ្សំ
# ក្នុងវិស័យកសិកម្ម
## នៃព្រះរាជាណាចក្រកម្ពុជា

ខែ ឧសភា **ឆ្នាំ២០១០**

អនុក្រុមស្រាវជ្រាវសេដ្ឋកិច្ចកសិកម្ម
នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(**ECOSOCC**)

ទីស្តីការគណៈរដ្ឋមន្ត្រី

# មាតិកា


| | ទំព័រ |
|---|---|
| I. **សេចក្តីផ្តើម** | 1 |
| II. **ស្ថានភាពដំណាំរួមផ្សំមួយចំនួន** | 1 |
| ២.១-ពោត | 2 |
| ២.២-ដំឡូងមី | 3 |
| ២.៣-ស្វាយចន្ទី | 5 |
| ២.៤-សណ្តែកសៀង | 7 |
| ២.៥-សណ្តែកបាយ | 7 |
| ២.៦-ល្ង | 7 |
| ២.៧ ផ្លែឈើ និងបន្លែ | 8 |
| ២.៧.១ ដំណាំឈើហូបផ្លែ | 8 |
| ២.៧.២ បន្លែ | 9 |
| III.**បញ្ហាប្រឈម និងឧបសគ្គ** | 10 |
| IV.**ភាពលទ្ធភាព** | 12 |
| V.**ផែនការគម្រោងកំហែង** | 13 |
| VI.**អនុសាសន៍** | 13 |
| VII. **សេចក្តីសន្និដ្ឋាន** | |

**References** 14

## បញ្ជីតារាង ទំព័រ


| | |
|---|---|
| តារាង១-អត្រារួមចំណែកជាភាគរយរបស់វិស័យកសិកកម្មក្នុងផលិតផលក្នុងស្រុកសរុបឆ្នាំ ១៩៩៩-២០០៩ | 1 |
| តារាង២-អត្រារួមចំណែកជាភាគរយរបស់អនុវិស័យនីមួយៗក្នុងវិស័យកសិកម្ម ឆ្នាំ ២០០៥-២០០៩ | 2 |
| តារាង៣-ជលផលទឹកសាប-សមុទ្រ និងវារីវប្បកម្មឆ្នាំ ២០០៥-២០០៩ (ជា ១០០០តោន) | 3 |
| តារាង៤-ចំនួនត្រីសមុទ្រដែលចាប់បានតាមខេត្ត ឆ្នាំ ២០០៥-២០០៩ (ជា ១០០០តោន) | 6 |
| តារាង៥-វារីវប្បកម្មត្រីសមុទ្រ និងទឹកសាបឆ្នាំ ១៩៨៥-២០០៤(ជា១០០០តោន) | 8 |
| តារាង៦-វារីវប្បកម្មត្រីសមុទ្រ និងទឹកសាបឆ្នាំ ២០០៥-២០០៩ | 8 |
| តារាង៧-ចំនួនត្រីទឹកសាប និងទឹកសមុទ្រដែលបានកែច្នៃឆ្នាំ ២០០៥-២០០៩ (ជាតោន) | 9 |
| តារាង៨-ចំនួនត្រីទឹកសាបកែច្នៃឆ្នាំ ១៩៩៥-២០០៩ (ជាតោន) | 10 |

តារាង៩-ចំនួនត្រីសមុទ្រសំខាន់ៗកែច្នៃឆ្នាំ ២០០៦-២០០៩ (ជាតោន) 11

តារាង១០-ចំនួនត្រីនាំចេញឆ្នាំ ២០០៥-២០០៩ (ជាតោន) 12

តារាង១១-សមត្ថភាពសិក្សារបស់បុគ្គលិកបច្ចេកទេស 13

តារាង១២-ករណីបទល្មើសឆ្នាំ ២០០៦-២០០៩ 13

តារាង១៣-ចំនួនកន្លែងភ្ញាស់កូនត្រី និងចំនួនកូនត្រីឆ្នាំ ២០០៦-២០០៩ (ជា ១០០០ក្បាល) 18

# សារៈសំខាន់នៃដំណាំរួមផ្សំក្នុងវិស័យកសិកម្ម

## ១. សេចក្តីផ្តើម

ស្រូវជាដំណាំចំបងនិងចាំបាច់សម្រាប់ចិញ្ចឹមជីវិតនិងក៏ជាផលិតផលនាំចេញធំបំផុតនៃវិស័យកសិកម្ម។ ទោះជារូមកម្ពុជាមានអតិរេកស្រូវក្តី ក៏នៅតែមានការខ្វះខាតស្បៀងអាហារតាមតំបន់ និងតាមរដូវកាលដោយសារកត្តាអាកាសធាតុ និងវិសមភាពរវាងប្រជាជនទីក្រុង និងជនបទ។ ដើម្បីធានាសុវត្ថិភាពការផ្គត់ផ្គង់ស្បៀង និងបង្កើនចំណូលរបស់ខ្លួន ប្រជាជននៅតំបន់ជនបទ ពឹងផ្អែកទៅលើចំណូលបន្ថែមដោយការដាំដំណាំរួមផ្សំ។

គោលបំណងនៃការស្រាវជ្រាវនេះ គឺ: ១. ដើម្បីសិក្សាអំពីទិដ្ឋភាពសេដ្ឋកិច្ច នៃដំណាំរួមផ្សំសំខាន់ៗ មួយចំនួនដូចជា ពោត ដំឡូងមី ស្វាយចន្ទី សណ្តែកសៀង សណ្តែកបាយ និងបន្លែ និង ២. កំណត់ អត្តសញ្ញាណកត្តាគន្លឹះមួយចំនួន ដែលអាចដើរតួក្នុងការបង្កើនផលិតភាព ពង្រីកផលិតកម្ម និងការធ្វើ ម៉ាខេធីង នៃផលិតផលទាំងនោះ ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ។

## ២. ស្ថានភាពដំណាំរួមផ្សំមួយចំនួន

### ២.១. ពោត

ដំណាំពោតត្រូវបានគេដាំច្រើននៅខេត្តកំពង់ចាម កណ្តាល និងខ្លះៗនៅ ក្រចេះ និងព្រៃវែង (តារាង១)។ ផ្ទៃដីដែលដាំដុះសរុបក្នុងឆ្នាំ ១៩៩៣ មានចំនួន ៤៨ ០០០ ហិកតា។ នៅទសវត្សរ៍ឆ្នាំ ៦០ ផ្ទៃដីដាំពោតមានចំនួន ១១៧ ០០០ ហិកតា។ នៅឆ្នាំ១៩៣០ ផ្ទៃដីដាំពោតមាន ២៣៥ ០០០ហិកតា ដើម្បីបំពេញសេចក្តីត្រូវការរបស់បារាំងសម្រាប់ជាចំណីសត្វ។ ក្នុងឆ្នាំ ១៩៦៧ កម្ពុជាបាននាំចេញពោត ៦៥ ០០០តោន ឯក្នុងឆ្នាំ ១៩៩០ នាំចេញតែ ៥ ៥០០ តោនប៉ុណ្ណោះ[1]។ ពោតមួយភាគធំ ត្រូវបានដាំតាមដងទន្លេ តំបន់ខ្ពង់រាប និងមួយចំនួនតូចក្នុងផ្ទៃប្រទេស ក្នុងលក្ខណៈ ជាអាហារបន្ទាប់បន្សំ និងប្រភពចំណូលបន្ថែម។

តាមទំនៀមទំលាប់មានពូជពោត២ប្រភេទ: ពោតដំណើប (Zea sacharata) និងពោតក្រហម (Zea indurata)។ រយៈពេលដាំដុះគឺរវាង ១០០-១១០ ថ្ងៃ។ ពូជទាំងពីរមានប្រភពពីប្រទេសមិកស៊ិក្ខ។ ទិន្នផលមធ្យមគឺប្រហែល ៤ត/ហ និងអាចឡើងដល់កំរិត ៩ត/ហ (តារាង១)។

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI) បានចាប់ផ្តើមធ្វើការងារកែលំអពូជពោតតាំងពីឆ្នាំ ២០០៣។ ពូជចំនួន ២៨ ត្រូវបានជ្រើសរើសសម្រាប់សិក្សាបន្ត។ ចាប់ពីឆ្នាំ ២០០៤

[1] Cambodia Business & Investment Handbook 1996

នៅប៉ៃលិន និងកណ្ដាល បានអនុវត្តពូជផ្សាំសាកល្បងចំនួន ១២។ លទ្ធផលនៃការពិសោធន៍លើ ប្រភេទដីផ្សេងៗ ក្នុងខេត្តកំពង់ចាម និងបាត់ដំបង បង្ហាញថាទិន្នផលមធ្យមនៃការ ដាំពោតបន្ទាប់ពីពោតទទួលបានទាប ១,៤៧ ត/ហា បើធៀបនឹងទិន្នផលមធ្យមនៃការដាំពោតបន្ទាប់ ពីសណ្ដែកសៀង: ២,១៥ ត/ហា។ ក្រៅពីនេះ ការប្រើជីអាហ្សូតក្នុងកំរិត ៨០គក្រ/ហា ដើម្បីបង្កើនទិន្នផលជាការចាំបាច់។ អនុសាសន៍ល្អបំផុតគឺថាកសិករគួរដាំពោតបន្ទាប់ពី ដំណាំអំបូរសណ្ដែក ឬល្ង មិនមែន

**តារាង១**: **ផ្ទៃដីដាំពោត**(A) **បរិមាណផលិតកម្ម**(B) **ទិន្នផលមធ្យមជាតោន**(C) **តាមបណ្ដាខេត្ត ២០០០ –២០០៧** (ពាន់ហិកតា និង ពាន់តោន)

| ឆ្នាំ | | ខេត្ត | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | បាត់តំបង | កំពង់ចាម | កំពង់ស្ពឺ | កំពង់ធំ | កណ្ដាល | ក្រចេះ | ព្រៃវែង | ពោធិសាត់ | រត្តនគីរី |
| ២០០០ | A | 23 | 13 | 0.5 | 1.0 | 14 | 2 | 3 | 0.5 | 0.4 |
| | B | 100 | 12 | 0.6 | 0.6 | 13 | 2 | 3 | 0.6 | 0.7 |
| | C | 4.4 | 1.6 | 1.2 | 0.9 | 1.5 | 1.7 | 1.5 | 1.2 | 1.7 |
| ២០០១ | A | 31 | 12 | 0.4 | 0.6 | 15 | 2 | 2 | 0.4 | 0.5 |
| | B | 133 | 3 | 0 | 0.6 | 7 | 1 | 2 | 0.1 | 0.0 |
| | C | 4.6 | 1.9 | 0 | 1.0 | 1.3 | 1.8 | 1.6 | 1.6 | 2.0 |
| ២០០២ | A | 33 | 11 | 0.7 | 1.7 | 14 | 2 | 2 | 0.5 | 0.5 |
| | B | 93 | 9 | 1.2 | 2.1 | 15 | 3 | 3 | 1.3 | 0.3 |
| | C | 2.9 | 1.1 | 1.9 | 1.4 | 1.6 | 1.5 | 1.6 | 3.3 | 1.5 |
| ២០០៣ | A | 44 | 8 | 0.9 | 1.0 | 14 | 1 | 2 | 0.5 | 0.6 |
| | B | 236 | 8 | 0.9 | 2.1 | 14 | 2 | 3 | 1.0 | 1.2 |
| | C | 5.5 | 1.4 | 1 | 2.4 | 1.6 | 1.8 | 1.9 | 2.1 | 2.3 |
| ២០០៤ | A | 45 | 5 | 0.4 | 0.4 | 14 | 2 | 2 | 0.4 | 0.2 |
| | B | 155 | 7 | 0.5 | 0.8 | 20 | 3 | 6 | 0.7 | 0.6 |
| | C | 4.3 | 1.3 | 1.5 | 2.0 | 1.9 | 1.9 | 2.6 | 2.0 | 2.8 |
| ២០០៥ | A | 39 | 7 | 0.9 | 0.5 | 13 | 2 | 1 | 0.4 | 0.5 |
| | B | 108 | 20 | 1.4 | 1.2 | 17 | 3 | 3 | 1.3 | 1.6 |
| | C | 4.7 | 2.9 | 1.7 | 2.2 | 1.9 | 1.9 | 2.6 | 3.2 | 3.5 |
| ២០០៦ | A | 42 | 12 | 0.5 | 0.7 | 14 | 2 | 2 | 0.5 | 0.3 |
| | B | 190 | 30 | 1.1 | 1.6 | 15 | 3 | 3 | 1.1 | 1.0 |
| | C | 4.5 | 3.0 | 2.0 | 2.3 | 1.4 | 1.7 | 2.9 | 3.9 | 3.8 |
| ២០០៧ | A | 65 | 13 | 1.1 | 1.1 | 16 | 2 | 3 | 0.5 | 0.6 |
| | B | 299 | 37 | 2.2 | 2.5 | 26 | 3 | 9 | 2.1 | 2.1 |
| | C | 4.6 | 2.8 | 2.0 | 2.2 | 1.6 | 1.7 | 2.8 | 3.7 | 3.5 |

Source: Adapted from Statistical Yearbook of Cambodia 2008

ពោតបន្ទាប់ពីពោតទេ។

### ២.២. ដំឡូងមី

ដំឡូងមីត្រូវបានដាំភាគច្រើននៅខេត្ត បាត់ដំបង ប៉ៃលិន កំពត កំពង់ចាម កំពង់ធំ តាកែវ ឧត្តរមានជ័យ និងមណ្ឌលគីរី។ ក្នុងឆ្នាំ ១៩៩៣ ដំឡូងមីបានផ្តល់ទិន្នផលមធ្យមប្រហែល ៥ត/ហ លើផ្ទៃដីសរុបមានចំនួន ១៦ ០០០ ហិកតា ធៀបនឹង ២១០០ ហិកតា ក្នុងឆ្នាំ ១៩៦៧[2]។ គេដាំដំឡូងមីលើទីរាងខ្ពស់ដែលមិនលិចទឹក។ ការកើនឡើងនៃផ្ទៃដីដាំដុះដំឡូងមី អាចដោយសារមានការធ្លាក់ចុះនៃផលិតកម្មស្រូវ តម្រូវការខ្ពស់ពីប្រទេសជិតខាង និងការកាប់ឆ្ការតំបន់ថ្មីសម្រាប់ដាំដុះដំណាំដែល

**តារាង២**: **ផ្ទៃដីដាំដុះ** (A) **ផ្ទៃដីប្រមូលផល** (B) **និងផលិតកម្ម**(C) **តាមប្រភេទដំណាំ ២០០០-២០០៧** (ពាន់ហិកតា និង ពាន់តោន)

| ឆ្នាំ | | ប្រភេទដំណាំ | | | | | |
|---|---|---|---|---|---|---|---|
| | | ពោត | ដំឡូងមី | បន្លែ | សណ្តែកបាយ | សណ្តែកសៀង | ល្ង |
| ២០០០ | A | 172 | 16 | 34 | 25 | 33 | 19 |
| | B | 57 | 15 | 32 | 23 | 33 | 18 |
| | C | 157 | 148 | 196 | 15 | 28 | 10 |
| ២០០១ | A | 80 | 14 | 35 | 29 | 32 | 20 |
| | B | 67 | 14 | 35 | 27 | 29 | 17 |
| | C | 186 | 142 | 185 | 17 | 17 | 9 |
| ២០០២ | A | 81 | 20 | 34 | 40 | 34 | 21 |
| | B | 72 | 19 | 33 | 35 | 29 | 18 |
| | C | 149 | 122 | 143 | 24 | 39 | 10 |
| ២០០៣ | A | 93 | 26 | 36 | 45 | 53 | 34 |
| | B | 84 | 25 | 36 | 43 | 52 | 32 |
| | C | 315 | 331 | 140 | 32 | 63 | 22 |
| ២០០៤ | A | 91 | 23 | 33 | 39 | 85 | 65 |
| | B | 73 | 23 | 32 | 37 | 84 | 57 |
| | C | 257 | 362 | 179 | 45 | 110 | 55 |
| ២០០៥ | A | 91 | 30 | 36 | 61 | 119 | 79 |
| | B | 71 | 30 | 36 | 54 | 116 | 71 |
| | C | 248 | 536 | 172 | 45 | 179 | 90 |
| ២០០៦ | A | 109 | 97 | 44 | 83 | 75 | 56 |
| | B | 105 | 96 | 44 | 76 | 64 | 47 |
| | C | 377 | 2,182 | 223 | 60 | 98 | 25 |
| ២០០៧ | A | 142 | 108 | 42 | 65 | 77 | 48 |
| | B | 142 | 108 | 42 | 65 | 77 | 41 |
| | C | 523 | 2,215 | 226 | 55 | 118 | 32 |

Source: Adapted from Statistical Yearbook of Cambodia 2008

[2]Cambodia Business & Investment Handbook 1996

ត្រូវការទីខ្ពស់។ លើសពីនេះគេក៏ប្រើដំឡូងមីសម្រាប់ចិញ្ចឹមជ្រូកផងដែរ។

តារាង ២(នៅទំព័រមុខ) បង្ហាញផ្ទៃដី និងផលិតកម្មដំឡូងមីពីឆ្នាំ ២០០០ដល់ ២០០៧។ ផលិតកម្មក្នុងឆ្នាំ ២០០៦ និង២០០៧ កើនឡើង ៤ដង បើធៀបនឹងឆ្នាំ ២០០៥ ដោយសារតែតម្រូវការនាំចេញខ្ពស់។នាពេលបច្ចុប្បន្ន ក្រុមហ៊ុន MH Bio Energy Co. ជាក្រុមហ៊ុនដែលប្រើប្រាស់ដំឡូងមីក្នុងស្រុកច្រើនជាងគេ។ ក្រុមហ៊ុននេះមានទីតាំងនៅព្រែកព្នៅ តាមបណ្តោយផ្លូវជាតិលេខ៥។ រោងចក្រនៃក្រុមហ៊ុននេះ មានតម្រូវការ ៥០,០០០ តោន/ឆ្នាំ លើដំឡូងមីស្ងួត នៅពេលបច្ចុប្បន្ន តែនៅពេលអនាគតសក្តានុពលតម្រូវការនៅចុងឆ្នាំ ២០១០អាចមានប្រមាណ ១៥០,០០០តោន/ឆ្នាំ ។

ដំឡូងមី១តោន ផលិតបានអេតាណុល៤៤៥លីត្រ។ រោងចក្រនោះផលិតបានអេតាណុលប្រហែល ២០០,០០០លីត្រ ក្នុង១ថ្ងៃ និងប្រើកម្មករប្រហែល ២០០នាក់។ ថ្លៃ fob អេតាណុលគឺ ៥០០ ដុល្លារ ស.រ.អ. /១០០០លីត្រ និងនាំចេញជារួមទៅអឺរុប។

ក្រុមហ៊ុន MH Bio Energy Co. មានដី ៨០០០ហិកតា ប៉ុន្តែមិនទាន់ដាំដំឡូងមីនៅឡើយ។ ដូចនេះហើយក្រុមហ៊ុនបានទិញវត្ថុធាតុដើមពីកសិករក្នុងខេត្ត បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន និង កំពង់ចាម។ តារាង៣ ខាងក្រោមបង្ហាញ ទិន្នផលមធ្យមក្នុង១ហិកតា។ ជារួម យើងសង្កេតឃើញថា ទិន្នផលមធ្យមនៃដំណាំនិមួយៗមានកំរិតទាប។

តួលេខក្នុងតារាង២ និង៣ បានបង្ហាញចំនួនដីដាំដុះដំណាំរួមផ្សំមានចំនួនតិចជាងតួលេខដែលមានក្នុងរបាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០០៩-២០១០។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ តួលេខពីប្រភពទាំងពីរ បានបង្ហាញថាក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ ចំនួនដីដាំដុះបានកើនឡើងជាលំដាប់។

**តារាង៣: ទិន្នផលមធ្យមក្នុង១ហិកតា នៃដំណាំសំខាន់ៗ (២០០០ –២០០៧)**

| ឆ្នាំ | ប្រភេទដំណាំ | | | | | |
|---|---|---|---|---|---|---|
| | ពោត | ដំឡូងមី | បន្លែ | សណ្តែកបាយ | សណ្តែកសៀង | ល្ងរ |
| **2000** | 2.75 | 9.67 | 6.13 | 0.65 | 0.85 | 0.55 |
| **2001** | 2.78 | 10.14 | 5.29 | 0.63 | 0.59 | 0.53 |
| **2002** | 2.07 | 6.42 | 4.33 | 0.68 | 1.34 | 0.55 |
| **2003** | 3.75 | 13.24 | 3.89 | 0.74 | 1.22 | 0.69 |
| **2004** | 3.50 | 15.74 | 5.59 | 1.22 | 1.31 | 0.96 |
| **2005** | 3.50 | 17.87 | 4.78 | 0.83 | 1.54 | 1.27 |
| **2006** | 3.59 | 22.73 | 5.07 | 0.79 | 1.53 | 0.53 |
| **2007** | 3.68 | 20.50 | 5.38 | 0.85 | 1.53 | 0.78 |

Source: Adapted from Statistical Yearbook of Cambodia 2008

គំរោងស្រាវជ្រាវអំពីដំឡូងមី ក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមជាផ្លូវការក្នុងខែមេសា ឆ្នាំ២០០៥ ក្រោមការគាំទ្រហិរញ្ញវត្ថុ ពីសំណាក់អង្គការ Centro International de Agricultura Tropical (CIAT) ដោយប្រើពូជដំណាំមួយចំនួនតូចមកពីប្រទេសថៃ។ ការដាំសាកល្បងនៅខេត្តកំពង់ចាម និងកំពង់ស្ពឺ ទទួលបានទិន្នផល ៣៨-៤៣ តោន/ហិកតា។ បើសិនជាការដាំមានចន្លោះរងរាងធំ ១មx១ម នោះ ទិន្នផលនឹងខ្ពស់ជាងការដាំដែលមានចន្លោះរង ០.៨៦ម x ០.៨៦ម។ ក្នុងការសាកល្បងនេះ ការដាំមួយគុម្ពក្នុងមួយពំនូក ឱ្យទោរដាក់គ្នាពីគុម្ពមួយទៅគុម្ពមួយនឹងផ្តល់ទិន្នផលខ្ពស់បំផុត។ របៀបដាំតាមទំលាប់ពីរគុម្ពក្នុងមួយពំនូកឱ្យទោរក្នុងទីសដៅផ្ទុយគ្នានឹងផ្តល់ទិន្នផលទាប។

តាមព័តមានបានពីការសម្ភាសន៍នៅខេត្តកំពង់ចាម ចំការអណ្តូង ការដាំដំឡូងមីក្នុងចំការកៅស៊ូ ទទួលបានទិន្នផល ១០ តោន/ហិកតា ប៉ុន្តែការដាំលើដីថ្មីទទួលបានទិន្នផល ៣០ តោន/ហិកតា។ ប៉ុន្តែ ទិន្នផលខ្ពស់លើដីថ្មីនេះ រក្សារបានមិនលើសពីរឆ្នាំទេ ដូច្នេះកសិករត្រូវតែអនុវត្តការដាំដុះផ្លាស់ជាមួយដំណាំផ្សេងៗ ដើម្បីរក្សាដីឲ្យនៅមានជីវជាតិល្អ។ ក្នុងការអនុវត្តជាក់ស្តែង កសិករគួរផ្លាស់វេនដំណាំ បន្ទាប់ពីពីរឆ្នាំ ដូចជាដំឡូងមីទៅជា លូវ ឬសណ្តែកសៀង ឬសណ្តែកបាយ ឬពោត។ មើមដំឡូងមី ដែលដកបានអាចលក់ស្រស់ ឬស្ងួត ឬកែច្នៃឱ្យទៅជាម្សៅ។ ថ្លៃកែច្នៃពីមើមសើម ឱ្យទៅជាកំណាត់ស្ងួតប្រហែល២៥ដុល្លារ/តោន។ ទាមទារមើមដំឡូងមីសើម ៣គ.ក្រ ដើម្បីផលិតដំឡូងមីស្ងួត ១គ.ក្រ។ ដំឡូងមីតិចតួចណាស់ ដែលបានកែច្នៃក្នុងស្រុកឱ្យទៅជាម្សៅ សម្រាប់ជាអាហារ ឬការប្រើប្រាស់។ ផលិតផលមួយភាគធំជាដំឡូងមីស្ងួតត្រូវបានលក់ឱ្យ ថៃ ឬវៀតណាម។ នាពេលបច្ចុប្បន្ន ក្រុមហ៊ុនឯកជនមួយកំពុងសាងសង់រោងចក្រកែច្នៃដំឡូងមីស្ងួត ឱ្យទៅជាម្សៅ។ ក្រុមហ៊ុននេះជាការចូលហ៊ុនគ្នារវាងអ្នកវិនិយោគកម្ពុជា និងចិន ដែលនឹងប្រើកម្មករប្រហែល ពី ៧០ ទៅ១០០នាក់។

## ២.៣. ស្វាយចន្ទី

ស្វាយចន្ទីគឺជារុក្ខជាតិដែលធន់នឹងលក្ខណ្ឌអាកាសធាតុនិងគុណភាពដីផ្សេងៗ។ ជាទូទៅគេច្រើនដាំវានៅលើដីដែលមិនសូវមានជីវជាតិ និងក្នុងលក្ខណ្ឌអាកាសធាតុស្ងួត។ ស្វាយចន្ទី ត្រូវបាននាំមក(ដាំ) ដោយជនជាតិព័រទុយហ្គាលតាំងពីយូរលង់ណាស់មកហើយ។ នៅប្រទេសកម្ពុជា ដំណាំនេះត្រូវបានដាំនៅលើផ្ទៃដីជិត ១០០០ហិកតា ជាពិសេសនៅខេត្តកំពត កោះកុង ស្វាយរៀងនិងកំពង់ចាម។ ចំណែកឯនៅខេត្តមណ្ឌលគីរី កំពង់ធំ កំពង់ស្ពឺ និងកំពង់ឆ្នាំងវិញកម្មវិធីអភិវឌ្ឍដំណាំស្វាយចន្ទីកំពុងដំណើរការ។ នៅខេត្តមណ្ឌលគីរីដំណាំនេះត្រូវបានគេដាំនៅលើផ្ទៃដីជាង ៦០០ហិកតា រួចមកហើយនៅឆ្នាំ១៩៩០។

គេប្រើប្រាស់គ្រាប់ស្វាយចន្ទីយ៉ាងទូលំទូលាយ និងទំនិញនេះមិនទាន់បំពេញតម្រូវការទីផ្សារអន្តរជាតិបានគ្រប់គ្រាន់នៅឡើយ។ ប៉ុន្តែមកដល់ពេលនេះ គេមិនទាន់ឱ្យតម្លៃខ្ពស់ដល់គ្រាប់ស្វាយចន្ទីកម្ពុជា ពីព្រោះវាមិនទាន់ឆ្លើយតបនឹងស្តង់ដារគុណភាព នៃទីផ្សារអន្តរជាតិ។

ផលិតកម្មក្នុងស្រុកត្រូវបានវាយតម្លៃថាមានចំនួន ៣៧០តោន ក្នុងឆ្នាំ ១៩៦៧[3]។ ប្រទេសកម្ពុជាយើងមានលក្ខណ្ឌយ៉ាងប្រសើរសម្រាប់ផលិតកម្ម គ្រាប់ស្វាយចន្ទី ប៉ុន្តែស្វាយចន្ទីជាច្រើនប្រភេទដែលដាំនៅស្រុកយើងទាមទារការកែលំអរដើម្បីបំពេញតម្រូវការទីផ្សារអន្តរជាតិ។

គ្រួសារតូចៗដែលដាំដុះស្វាយចន្ទី បានយល់ដឹងអំពីបច្ចេកទេសនៃការដាំដំណាំនេះ និងកំពុងបង្កើនការដាំដុះ។ ផ្ទៃដីមានជាច្រើនដើម្បីពង្រីកក្រឡាផ្ទៃសម្រាប់ការដាំដុះ ដូច្នេះ អ្វីដែលជាតម្រូវការជាបន្ទាន់ គឺការផ្តល់នូវការកែលំអរសម្ភារៈកសិកម្ម សេវាពិគ្រោះយោបល់ និងការបង្កើតឱ្យមានឧបករណ៍កែច្នៃខ្ពស់។

មានទិន្នន័យតិចតួចដែលអាចប្រមូលបានពីគ្រប់ប្រភព។ កិច្ចសម្ភាសន៍ដែលបានពីប្រតិបត្តិករនៃចំការស្វាយចន្ទីនៅស្ពន់ខេត្តកំពង់ចាមបានបំភ្លឺពត៌មានខ្លះៗដែលបង្ហាញថាចាប់ពី ឆ្នាំ១៩៩៣មានផ្ទៃដីចំការស្វាយចន្ទីប្រមាណ២០០០ហិកតា ប៉ុន្តែមិនទាន់បានប្រើប្រាស់ជីរទេ ទើបតែចាប់ពីឆ្នាំ២០០៤មានការប្រើប្រាស់ជីរក្នុងកំរិត១គីឡូក្រាម/១ដើម/១ដង ហើយក្នុង១ឆ្នាំដាក់ជីរ២ដង។ បច្ចុប្បន្ននេះដើមស្វាយចន្ទីដែលនៅលើដីជាង១០០០ហិកតាត្រូវបានគេកាត់ចោល ពិព្រោះវាមិនផ្តល់ផលល្អ។ នៅលើដីនេះត្រូវបានគេជំនួសដោយគ្រាប់ពូជថ្មីដែលជ្រើសចេញពីពូជដែលមានស្រេចហើយនៅក្នុងចំការនោះ។ ដំណាំថ្មីផ្តល់ផល៣ឆ្នាំក្រោយ ក្នុងកំរិតជិត៧០០គីឡូក្រាម/ហិកតា ជាផ្លែស្រស់។ គ្រួសារឯកជនដែលមានទំហំដីពី១ ទៅ ៣ហិកតា បានទទួលផលតែ ជិត២០០គីឡូក្រាម/ហិកតាប៉ុណ្ណោះ។

រដូវបេះផ្លែចាប់ផ្តើមពីខែកុម្ភៈនិង ចប់នៅខែ ឧសភា។ ខែមិនាគឺជាខែមមាញឹកជាងគេដែលមានកម្មករធ្វើការ១ថ្ងៃៗប្រមាណ១០០០នាក់។ អ្នកប្រមូលគ្រាប់ស្វាយចន្ទីទទួលបាន១៥០រៀលក្នុងមួយគីឡូក្រាម។ ជាទូទៅផលិតផលដែលទទួលបាន ត្រូវលក់ឱ្យទៅពាណិជ្ជករវៀតណាមតាមតំលៃដែលអ្នកទិញកំណត់។ ដោយសារការសម្ងួតនិងរក្សាទុកបានល្អ ទិន្នផលដែលផលិតនៅក្នុងចំការមានតំលៃខ្ពស់ជាងរបស់អ្នកភូមិ។

គ្រាប់ស្វាយចន្ទីត្រូវនាំយកទៅវៀតណាមដើម្បីកែច្នៃបន្តៈ បំបែកគ្រាប់និងសម្អាត ហើយយកគ្រាប់ចេញ។ ក្នុង១គីឡូក្រាមគ្រាប់ស្វាយចន្ទីស្ងួតអាចផ្តល់ទិន្នផលសម្រេចតែ៣០០ក្រាមប៉ុណ្ណោះ។ កាលពី៣ឆ្នាំមុនក្រុមហ៊ុនបានសាកល្បងលក់គ្រាប់ស្វាយចន្ទីពី៦០០តោនទៅ៧០០តោនឱ្យក្រុមហ៊ុន

[3] Cambodia Business & Investment Handbook 1996

ឥណ្ឌា ឆ្លងកាត់ផែក្រុងព្រះសីហនុ ក៏ប៉ុន្តែបែបបទនៃការនាំចេញបានជួបការលំបាកយ៉ាងខ្លាំងដែលជាហេតុធ្វើឲ្យក្រុមហ៊ុនឥណ្ឌាផ្អាកទិញផលិតផលនេះតទៅទៀត។

ដូចគ្នានឹងករណីដំឡូងមីដែរ អ្នកដាំស្វាយចន្ទីទទួលជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុ តិចតួចណាស់ ឬមិនបានទទួលទាល់តែសោះពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬពីភ្នាក់ងារណាមួយ។

## ២.៤ សណ្តែកសៀង

សណ្តែកសៀងត្រូវបានគេដាំជាពិសេសនៅខេត្តកំពង់ចាមនៅលើផ្ទៃដីប្រមាណ ១៦,០០០ ហិកតា នៅឆ្នាំ១៩៩៣ ក៏ប៉ុន្តែកាលពីឆ្នាំ១៩៦៧ មានតែ ៨១០០ហិកតាប៉ុណ្ណោះ។ នៅឆ្នាំ១៩៩០កម្ពុជាបាននាំចេញសណ្តែកសៀងជាផ្លូវការ ១៥,០០០តោន។ ផលិតផលជាមធ្យម ក្នុងចន្លោះពី ០,៩ តោនទៅ ១,៥តោន/ហិកតា[4]។ ជាក់ស្តែងសណ្តែកសៀងត្រូវបានគេដាំតែឯង នៅលើខ្ពង់រាប នៃខេត្តកំពង់ចាម។ តួលេខថ្មីៗភាគច្រើនមាននៅតារាង២ និង៣នៅទំព័រខាងមុខ។ ការនាំចេញសណ្តែកសៀងក្នុង១ឆ្នាំៗមានប្រមាណ ៦០,០០០តោន។ ការពិសោធន៍កំណត់ប្រភេទពូជត្រូវការឲ្យមានការជ្រើសរើសគ្រាប់សណ្តែកសៀងផ្សេងៗ ដែលត្រូវនឹងប្រព័ន្ធបរិស្ថាននៅប្រទេសកម្ពុជាបានចាប់ផ្តើមនៅដើមឆ្នាំ២០០១។ មានពូជចំនួន១១ប្រភេទផ្សេងៗ ដែលត្រូវបានវាយតំលៃកាលពីឆ្នាំ ២០០៣ នៅខេត្តកំពង់ចាម និងតាកែវ។ គំរោងនេះនៅកំពុងបន្តសិក្សានៅឡើយ។

## ២.៥ សណ្តែកបាយ

សណ្តែកបាយត្រូវបានគេដាំនៅលើទំហំដីតូចៗស្ទើរតែគ្រប់កន្លែងនៃផ្ទៃប្រទេស ជាពិសេសនៅខេត្តកំពង់ចាម កំពង់ឆ្នាំង តាកែវ និងកណ្តាល។ ការដាំដុះដំណាំនេះធ្វើឡើងនៅក្នុងប្រព័ន្ធបរិស្ថានកសិកម្មបីប្រភេទ: ពេលទឹកស្រក តាមឆ្នេរទន្លេ និងលើដីព័ណខ្មៅ និងព័ណក្រហម។ ផ្ទៃដីសរុបដែលបានដាំសណ្តែកបាយនៅឆ្នាំ១៩៩៣ មាន២៥,០០០ហិកតា បើធៀបនឹងឆ្នាំ១៩៦៧ដែលមានតែ ៥,០០០ហិកតា។ ផលិតផលមធ្យមមាន៥០០គីឡូក្រាម/ហិកតា។ នៅឆ្នាំ១៩៦៧កម្ពុជាបាននាំចេញផលិតផលនេះលើសពី៦,០០០តោន[5] ។តួលេខថ្មីៗភាគច្រើនមាននៅតារាង២ និង៣នៅទំព័រខាងមុខ។ ការពិសោធន៍កំណត់ប្រភេទពូជត្រូវការឲ្យមានការជ្រើសរើសពូជគ្រាប់សណ្តែកបាយផ្សេងៗដែលត្រូវនឹងប្រព័ន្ធបរិស្ថានកម្ពុជា បានចាប់ផ្តើមនៅឆ្នាំ២០០៣។ មានប្រភេទចំនួន១១ផ្សេងៗត្រូវបានគេធ្វើតេស្តនៅខេត្តកំពង់ចាម និងតាកែវ។ គំរោងនេះនៅកំពុងដំណើរការ។

[4] Cambodia Business & Investment Handbook 1996
[5] Cambodia Business & Investment Handbook 1996

## ២.៦ ល្ងរ

ល្ងរត្រូវបានគេដាំជាពិសេសនៅខេត្តកំពង់ចាម កណ្តាល តាកែវ និងព្រៃវែង។ គេដាំវានៅលើដីមុនទឹកជំនន់ និងពេលទឹកស្រក។ កាលឆ្នាំ១៩៦៧ នៅលើដីខ្ពង់រាបចំការលើ ដែលជាកន្លែងដាំល្ងរពីមុន បច្ចុប្បន្នត្រូវបានគេផ្លាស់ដាំសណ្តែកបាយវិញ។ នៅឆ្នាំ១៩៩៣ ផ្ទៃដីសរុបដាំល្ងរមាន១៣,០០០ហិកតា ហើយការនាំចេញល្ងរមាន៦,៦០០តោន និងផលិតផលមធ្យមជិត៩០០គីឡូក្រាម/ហិកតា[6]។ CARDI បានចាប់ផ្តើមធ្វើការពិសោធន៍ដើម្បីកែលំអរគ្រាប់ពូជល្ងរនៅឆ្នាំ២០០៥។ មានគ្រាប់ពូជ៦ប្រភេទផ្សេងៗគ្នាត្រូវបានសាកល្បងដាំជាមុននៅខេត្តកំពង់ចាម និងបាត់ដំបង។ តួលេខថ្មីៗភាគច្រើនមាននៅតារាង២ និង៣នៅទំព័រខាងមុខ។

## ២.៧ ផ្លែឈើ និងបន្លែ

### ២.៧.១ ដំណាំឈើហូបផ្លែ

ឈើហូបផ្លែត្រូវបានគេដាំនៅគ្រប់ទីកន្លែងនៃផ្ទៃប្រទេស ជាពិសេសនៅជុំវិញផ្ទះ។ ដំណាំនេះមានច្រើនប្រភេទណាស់ហើយស្ទើរតែគ្រប់ដំណាំត្រូពិចគេឃើញមានដុះនៅប្រទេសកម្ពុជា។ នៅមិន

**តារាង៤**: **ផលិតផលដំណាំឈើហូបផ្លែនៅកម្ពុជា**(**១៩៦៧**)

| ប្រភេទ | ផ្ទៃដីដាំដំណាំ ( ហ.) | ផលិតផល(តោន) |
|---|---|---|
| ចេក | 20,800 | 133,000 |
| ម្នាស់ | 2,200 | 153,000 |
| ស្វាយ | 7,100 | 48,400 |
| ក្រូចពោធិសត្វ | 2,800 | 23,300 |
| ក្រូចថ្លុង | 500 | 8,400 |
| ក្រូចឆ្មារ | 400 | 5,200 |
| ក្រូចឃ្វិច | 300 | 1,800 |
| ស្វាយចន្ទី | 1,200 | 400 |
| មាន | 800 | 1,200 |
| សាវម៉ាវ | 300 | 400 |
| ធូរេន | 300 | 700 |
| សរុប | **36,300** | **236,500** |

Source: L. Tichit, L’Agriculture Au Cambodge, 1981

[6] Cambodia Business & Investment Handbook 1996

ទាន់មានតួលេខផ្លូវការអំពីទំហំផ្ទៃដីដាំដុះបច្ចុប្បន្ន និងផលិតផលសម្រាប់ដំណាំនេះទេ។ តួលេខប៉ាន់ស្មានឆ្នាំ១៩៦០ បានបង្ហាញថាមានផ្ទៃដីសរុបចំនួន ៣៦,០០០ហិកតា ដែលក្នុងនោះមានដំណាំចេក ៥៧% ស្វាយ ១៩% ក្រូច ១១% ម្នាស់ ៦% ស្វាយចន្ទី ៣% និងដំណាំផ្សេងទៀត (សាវមាវ ធូរេន) តិចជាង៤%។ នៅឆ្នាំ ១៩៦៧ ខេត្តបាត់ដំបងមាន៣៨%នៃផ្ទៃដីសរុប គ្របដណ្តប់ដោយដំណាំឈើហូបផ្លែ ដែលក្នុងនោះបានផ្តល់ផលជាអំបូរក្រូច ៦០% ស្វាយ ៥០% និងចេក ៩០%(តារាង៤)។

ខេត្តកំពង់ចាមដាំដំណាំចេក និងម្នាស់ច្រើនលើសលុបជាងគេសម្រាប់បំរើទីផ្សារក្នុងស្រុក។ ខេត្តកំពត ជាខេត្តផលិតធូរេន និងសាវមាវដែលមានគុណភាពល្អលើសគេ។

ផលលំបាកចំបងក្នុងផលិតកម្មផ្លែឈើគឺទាក់ទងនឹងដើមកូនដំណាំមានគុណភាពទាប ការគ្រប់គ្រងជំងឺ ឬសត្វល្អិតមិនបានល្អ កិច្ចការស្រោចស្រប់ក៏មិនគ្រប់គ្រាន់ និងមិនទាន់មានបច្ចេកទេសគ្រប់គ្រាន់ក្នុងការផ្សាំ និងកាត់មែកធាង។ ទំហំទីផ្សារក្នុងស្រុកមានកំណត់តូចតាច ឯប្រទេសជិតខាងបានរៀបចំហេដ្ឋារចនាសម្ព័នដើម្បីនាំចេញផលិតផលនេះបានល្អរួចស្រេចទៅហើយ។ នៅឆ្នាំ២០០៣ មានការធ្វើតេស្តផ្សេងៗដើម្បីកែលំអរគុណភាពស្វាយ ចេក និងឥឡឹកដែរ។

### ២.៧.២ បន្លែ

បន្លែត្រូវបានដាំដុះនៅគ្រប់ទីកន្លែងនៃផ្ទៃប្រទេស។ មានការដាំលើទំហំផ្ទៃដីតូចៗទុកសម្រាប់បំពេញតំរូវការតាមផ្ទះនិមួយៗ ចំណែកការដាំតាមឆ្នេរទន្លេក្បែរទីក្រុង និងទីផ្សារ ក្នុងគោលបំណងបំរើមូលដ្ឋានទីផ្សារតាមតំបន់។ បន្លែត្រូវបានគេបរិភោគយ៉ាងច្រើននៅប្រទេសកម្ពុជា ហើយក៏ជាមូលដ្ឋានទីផ្សារក្នុងស្រុកយ៉ាងរឹងមាំ។ ផ្ទៃដីដាំដុះ និងផលិតកម្ម មានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ មូលហេតុដោយសារជំងឺ គ្រោះមហន្តរាយធម្មជាតិ និងការប្រែប្រួលតម្លៃទីផ្សារ។

គេប៉ាន់ស្មានថាតម្រូវការបន្លែសរុបក្នុងមួយឆ្នាំៗមាន ១លានតោនសម្រាប់បំពេញសេចក្តីត្រូវការក្នុងស្រុក ក្នុងនោះប្រមូលបានពីព្រៃ ២៥% ប្រមូលបានពីការដាំលើផ្ទៃដី ២៥% និង៥០%ទៀតបានពីការនាំចូលពីប្រទេសជិតខាង ដូចជាវៀតណាម និងថៃ។ យើងមិនទាន់មានតួលេខថ្មីនៅឡើយ ប៉ុន្តែនៅឆ្នាំ១៩៦៧ ផ្ទៃដីដាំដុះបន្លែមាន៤៣,០០០ហិកតា (៧៣%នៃផ្ទៃដីប្រើប្រាស់ក្នុងរដូវប្រាំង)។ ខេត្តដែលមានផលិតកម្មបន្លែច្រើនជាងគេ (បើគិតជា%នៃផ្ទៃដីដាំដុះបន្លែសរុប) មានខេត្ត: កណ្តាល(៣៩%) កំពង់ឆ្នាំង (១៧%) កំពង់ស្ពឺ (១០%) ព្រៃវែង (៨%) កំពង់ចាម (៦%) កំពង់ធំ (៥%)[7]។ ការស្រាវជ្រាវមួយចំនួនក្នុងការកែលំអរគុណភាពដំណាំបានចាប់ផ្តើមឡើងនៅឆ្នាំ២០០៣ ចំពោះប៉េងប៉ោះ និងម្ទេះ។

[7] Cambodia Business & Investment Handbook 1996

## ៣. បញ្ហាប្រឈម និងឧបសគ្គ

ដូចគ្នានឹងការអភិវឌ្ឍដំណាំស្រូវ ការអភិវឌ្ឍដំណាំកសិកម្មរួមផ្សំ ជួបការលំបាកមួយចំនួន ដូចខាងក្រោម:

១. **ការផ្តល់មូលនិធិ** សម្រាប់ការស្រាវជ្រាវកសិកម្ម ការបណ្តុះបណ្តាល និងការពង្រីកសមត្ថភាព នៅមិនទាន់សមស្រប។ មូលនិធិស្រាវជ្រាវភាគច្រើនផ្គត់ផ្គង់ដោយអ្នកផ្តល់ជំនួយអន្តរជាតិ។ ម្យ៉ាងទៀត ការស្រាវជ្រាវ និងការផ្សព្វផ្សាយដែលមានសារប្រយោជន៍សម្រាប់ការអនុវត្តន៍ (adaptive research) ដែលបាន ធ្វើរួចហើយ នៅមានលក្ខណៈមិនទាន់ស៊ីជំរៅនៅឡើយ។

២. **ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេស** ចំពោះអ្នកដាំដុះដំណាំទីផ្សារ ដូចជាពោត ដំឡូងមី សណ្តែកបាយ សណ្តែកសៀង ល្ង នៅមានកំរិតនៅឡើយ។ កសិករមួយចំនួនធំ ពឹងផ្អែកលើ ហិរញ្ញវត្ថុ និងបច្ចេកទេសអនុវត្តផ្ទាល់ខ្លួន។ មួយដងមួយកាល ពួកគេទទួលបានការណែនាំ បច្ចេកទេសពី អ្នកទិញដំណាំមកពីប្រទេសថៃ និងវៀតណាមខ្លះៗ។ ទាំងកសិករ និងទាំងក្រុមហ៊ុនកសិកម្ម មិនមានធនធានគ្រប់គ្រាន់ ដើម្បីទិញធាតុចូលដែលចាំបាច់សម្រាប់ផលិតកម្មបច្ចេកទេសទំនើប។

៣. **ទិន្នផលទាបនៃផលិតកម្ម:** ឧទាហរណ៍ដូចជា ដំឡូងមី អាចផលិតបានរហូតដល់ ៤០តោនក្នុង ១ហិកតា ប៉ុន្តែទិន្នផលមធ្យមជាក់ស្តែងមានកំរិតប្រហែលតែ ២០តោន ក្នុង១ហិកតាប៉ុណ្ណោះ។ ការធានាគុណភាពនៃធាតុចូលមានកំរិត និងការមិនមានការធានាគុណភាពនៃធាតុចេញនៅទីបំផុតបានធ្វើឲ្យតម្លៃផលិតផលធ្លាក់ចុះជាលំដាប់។

៤. **ទាក់ទងនឹងការធ្វើធុរកិច្ច:** ធនាគារពិភពលោកបានចាត់ថ្នាក់ប្រទេសកម្ពុជាជាប់លេខទី១៤៥ ដែលជាប្រទេសមានបរិយាកាសធុរកិច្ចលំបាក ក្នុងចំណោមប្រទេស១៨៣ដែលបានធ្វើអង្កេត។ ប្រទេសជិតខាងដូចជា ថៃ និងវៀតណាម បានជាប់លេខ ទី១២ និងទី៩៣ រៀងគ្នា។ ជាមួយនោះផងដែរ កម្ពុជាស្ថិតនៅលំដាប់លេខទី៩៥ សម្រាប់ការចាប់ផ្តើមធ្វើវិនិយោគ ពីព្រោះទាមទាររយៈពេល ៨៥ថ្ងៃរត់ការ និងអស់ថ្លៃខ្ពស់។

៥. **កសិឧស្សាហកម្ម** សម្រាប់កែឆ្នៃផលិតផលកសិកម្ម នៅមិនទាន់អភិវឌ្ឍដោយសារ ការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ និងថ្លៃអគ្គិសនីខ្ពស់។ ក្នុងឆ្នាំ ២០០៩ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) បានរាយការណ៍ថា មានប្រជាជនតែ២០% ប៉ុណ្ណោះមានលទ្ធភាពបានប្រើអគ្គិសនី។ យ៉ាងណាមិញ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពចំពោះអគ្គិសនី និងប្តេជ្ញាផ្តល់លទ្ធភាពប្រើប្រាស់អគ្គិសនីរហូតដល់ ៧០%នៃប្រជាជន ក្នុងឆ្នាំ ២០២០ខាងមុខ តាមរយៈ គំរោងអភិវឌ្ឍវារីអគ្គិសនីតាមបណ្តោយទន្លេមេគង្គ និងដៃរបស់វា។

៦. **ការនាំចេញផលិតផលកសិកម្ម** ពីកម្ពុជានៅមានកំរិត ដោយសាររបាំងមួយចំនួនដូចជា:

ក. "អ្វីៗគ្រប់យ៉ាងលើកលែងសម្ភារៈសឹក - EBA" : លក្ខខណ្ឌអនុគ្រោះនេះដែលបាន ចាប់ផ្តើមក្នុងឆ្នាំ ២០០១ អនុញ្ញាតឱ្យ ទំនិញកម្ពុជាស្ទើរតែ១០០% នាំចេញទៅ សហគមអឺរ៉ុបបាន។ តែលក្ខខណ្ឌអនុគ្រោះទាមទារឲ្យបំពេញលក្ខខណ្ឌពីរប្រភេទ គឺ ភាពពិតប្រាកដនៃប្រភពដើមកំណើត របស់ផលិតផល (rule of origin- RoR) និងវិធានការអនាម័យ និងរុក្ខអនាម័យ (Sanitary and Phyto-sanitary (SPS) measures) ។

ខ. សហរដ្ឋអាមេរិក នៅតែជាទីផ្សារនាំចេញធំបំផុតរបស់កម្ពុជា។ កម្មវិធីរបស់ ស.រ.អ. ក្នុង ឆ្នាំ១៩៧៦ បានផ្តល់លក្ខខណ្ឌអនុគ្រោះពន្ធគយសម្រាប់ទំនិញ៣៤០០មុខ ពីប្រទេសកំពុងអភិវឌ្ឍន៍ ចំនួន ១៣៦។ ជាបន្ថែម មុខទំនិញចំនួន១៨០០ទៀត ត្រូវបានអនុញ្ញាតសម្រាប់ការអនុគ្រោះពន្ធគយ ក្នុងឆ្នាំ១៩៩៦។ តែគួរឱ្យសោកស្តាយណាស់ នៅឆ្នាំ ២០០៦មានការវាយតម្លៃថា មានតែ ០.២៥% នៃ ការនាំចេញរបស់កម្ពុជាប៉ុណ្ណោះ ត្រូវបានផ្តល់ការអនុញ្ញាតិសម្រាប់ប្រព័ន្ធអនុគ្រោះពន្ធទូទៅនេះ (General System of Preferences -GSP)ក្រោយពីបានទទួលស្គាល់ថាមានលក្ខខណ្ឌត្រឹមត្រូវតាម ផ្លូវច្បាប់។

គ. ប្រទេសជប៉ុនផ្តល់ ប្រព័ន្ធអនុគ្រោះពន្ធទូទៅ ឱ្យប្រទេសកំពុងអភិវឌ្ឍចំនួន១៤២ និង១៥ តំបន់។ ខុសពី ស.រ.អ. និងសហគមអឺរុប ជប៉ុនមិនអនុញ្ញាត ASEAN cumulations ដល់កម្ពុជាទេ ខណៈពេលអនុវត្ត **វិធាននៃប្រភពដើមកំណើត** (rule of origin) ប៉ុន្តែជប៉ុនផ្តល់ផលប្រយោជន៍ទាំងអស់ នោះឱ្យប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងវៀតណាម។ ទំនិញទាំងអស់ដែលបានផលិត មួយចំណែកក្តី ឬទាំងស្រុងក្តី ចេញពីវត្ថុធាតុដើមដែលបាននាំចូលពីប្រទេសផ្សេងៗ ឬពីមិនដឹងប្រភព ត្រូវបានចាត់ទុកថា ជាទំនិញនាំចេញពីប្រទេស-ទទួលផល ប្រសិនបើវត្ថុធាតុដើម ឬចំណែកវត្ថុធាតុ ដើម បានឆ្លងកាត់ការកែច្នៃក្នុងប្រទេសនោះ។

ផ្នែកកសិកម្ម និងនេសាទ ប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP) ជាគោលការណ៍ មិនត្រូវបានផ្តល់ទេ ពីសំណាក់ប្រទេសជប៉ុន ដើម្បីការពារអ្នកផលិតក្នុងស្រុក។

ឃ. អាស៊ាន: កម្ពុជាជាសមាជិកនៃកិច្ចព្រមព្រាងពាណិជ្ជកម្មតំបន់ហៅថា តំបន់ពាណិជ្ជកម្ម សេរីអាស៊ាន (ASEAN Free Trade Area)។ ប្រទេសអាស៊ានបានធ្វើសមាហរណកម្មទីផ្សាររបស់គេ យ៉ាងស្រស្រាក់ស្រស្រាំ សម្រាប់ពាណិជ្ជកម្មទំនិញ និងសេវា តាមរយៈកម្មវិធី អត្រាអនុគ្រោះ ប្រសិទ្ធភាពពន្ធគយរួម (CEPT) ចុះហត្ថលេខាក្នុងឆ្នាំ ១៩៩២។ អត្រាមធ្យមសម្រាប់ អាស៊ាន-៦ ក្រោម កិច្ចព្រមព្រៀង CEPT សព្វថ្ងៃចុះមកត្រឹម ១.៥១% ពី ១២.៧៦%។ ផលិតផលមួយចាត់ទុកថា ទទួល បានសម្បទាន CEPT ពេលដែលផលិតផលនោះ បានទទួល អត្រាពន្ធគយអនុគ្រោះទាប ពីប្រទេស អាស៊ានមួយទៀត។ តាមរយៈកិច្ចព្រមព្រៀងនេះ កម្ពុជាអាចទទួលបានឧត្តមភាពច្រើន ក្នុងការនាំចេញ

ផលិតផលកសិកម្ម ប៉ុន្តែកម្ពុជានៅតែរងការលំបាក ជាមួយនឹង វិធានការអនាម័យ និងរុក្ខអនាម័យ (SPS measures)។

ង. កម្ពុជាបានទទួលការអនុគ្រោះពន្ធ (preferential access) ទៅកាន់ទីផ្សារចិន ដោយសារកម្មវិធី "Early-Harvest" អាស៊ាន-ចិន។ ប៉ុន្តែរបាំងនៃការនាំចូល (access barriers) ដែលមានគឺស្ថិតក្នុងវិធានការអនាម័យ និងរុក្ខអនាម័យ (SPS measures) ។

## ៤. ការលទ្ធភាព

យើងអាចទទួលជ័យជំនះបានលើបញ្ហាប្រឈម និងឧបសគ្គដែលបានកត់សំគាល់ខាងលើ តាមរយៈចំណាត់ការសមស្របពីសំណាក់តួអង្គទាំងអស់: រដ្ឋាភិបាល កសិករ(អ្នកដាំដុះ និងអ្នកកែច្នៃ) គ្រឹះស្ថានហិរញ្ញវត្ថុ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ។

ចំណាត់ការទាំងនោះមានដូចជា:

១. បង្កើនការឧបត្ថម្ភមូលនិធិគ្រប់គ្រាន់ចំពោះក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ដើម្បី

**តារាង៥: ការវាយតម្លៃទីផ្សារបច្ចុប្បន្ន និងសក្តានុពលរបស់វាសម្រាប់ដំណាំទីផ្សារ**

| ផលិតផល | ការវាយតម្លៃ | ទីផ្សារបច្ចុប្បន្ន | ទីផ្សារគួរឱ្យចាប់អារម្មណ៍បំផុត | ប្រទេសផ្សេងទៀត |
|---|---|---|---|---|
| ដំឡូងមី | ខ្ពស់ | ឥណ្ឌូណេស៊ី<br>ម៉ាលេស៊ី<br>វៀតណាម ថៃ | ចិន<br>ហ្វាំងឡង់ | អាហ្វ្រិកខាងត្បូង<br>អង់គ្លេស<br>ហ្គាមប៊ី |
| គ្រាប់ស្វាយចន្ទី | មធ្យម | ស.រ.អ.<br>កាណាដា<br>វៀតណាម | អូស្ត្រាលី<br>បារាំង បែលហ្ស៊ិក<br>ថៃ | កូរ៉េខាងត្បូង<br>សឹង្ហបុរី<br>ឥណ្ឌា<br>ឥណ្ឌូណេស៊ី |
| សណ្តែកសៀង | មធ្យម | ថៃ សឹង្ហបុរី<br>វៀតណាម | ចិន ជប៉ុន តៃវ៉ាន់<br>ទួរគី អាលឺម៉ង់ | |
| ពោត | ទាប | ថៃ តៃវ៉ាន់ | អេស្ប៉ាញ អ៊ីតាលី<br>ហុល្លង់ បារាំង<br>ឥណ្ឌូណេស៊ី<br>វេណេស៊ុយអេឡា<br>អូទ្រីស | |

Source: Adapted from Cambodia's Updated Trade Integration Strategy: DTIS 2007

ជំរុញ និងបង្កើនដល់ការស្រាវជ្រាវដំណាំសំខាន់ៗទាំងអស់នេះ រួចហើយផ្សព្វផ្សាយចែកជូនជាព័តមានដល់ប្រជាកសិករសម្រាប់ការអនុវត្តឱ្យមានប្រសិទ្ធិភាព។

២. ជួយដល់កសិករដាំដំណាំក្នុងការបង្កើតសហាគមន៍ដើម្បីពង្រឹងផលិតកម្ម និងតំលៃភោគផលរបស់ខ្លួន។

៣. ជំរុញលទ្ធភាពកំចី (loan access) ដល់កម្មសិទ្ធករខ្នាតមធ្យម និងធំ ដោយផ្តល់ឥណទានសមស្រប ដើម្បីអភិវឌ្ឍបរិក្ខារបច្ចេកទេសកែច្នៃ និងលក្ខខណ្ឌស្តុកទុក និងបង្កើនការប្រមូល ភោគផលដំណាំដំបូងឱ្យទាន់ពេលវេលា ដូចជាពោត ដំឡូងមី គ្រាប់ស្វាយចន្ទី បង្ការការគេចពន្ធខុសច្បាប់ទៅប្រទេសជិតខាង។

៤. បង្កើនទីផ្សារនាំចេញ (តារាង៥នៅទំព័រមុខ)

៥. កាត់បន្ថយឲ្យដល់កំរិតអប្បបរិមា នូវការងារក្រដាស់ស្នាមសម្រាប់ការនាំចេញផលិតផល។ អ្វីដែលសំខាន់បំផុត ស្ថាប័នដែលចេញឯកសារ អនាម័យ និងរុក្ខអនាម័យ (SPS documents) ត្រូវតែកំណត់តួនាទីឲ្យបានល្អ និងមានការទទួលស្គាល់ពីអន្តរជាតិ។

## ៥. ការគំរាមកំហែង

ការគំរាមកំហែងចំបងនាពេលបច្ចុប្បន្ន ក្នុងការសម្រេចជោគជ័យដើម្បីការអភិវឌ្ឍ ដំណាំកសិកម្មរួមផ្សំមានដូចខាងក្រោម:

ក. ឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដាក់មុខទំនិញទាំងនោះជាអាទិភាពចំបងមួយក្នុងចំណោមអាទិភាពផ្សេងៗ។

ខ. ការខ្វះខាតការគាំទ្រពីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការជួយដល់កសិករក្នុងការបង្កើតសហាគមន៍ ដើម្បីផ្តល់ចំណេះដឹងបច្ចេកទេស សម្រាប់ការដាំដុះដំណាំ ការកែច្នៃ ការធ្វើម៉ាខេធីង និងការបង្កើតលទ្ធភាពកំចី (locating the access to loan)។

គ. ការបង្កើតស្ថាប័នគួរជាទីទុកចិត្ត សម្រាប់ចេញវិញ្ញាបនបត្រ អនាម័យ និងរុក្ខអនាម័យ (SPS) ដែលអន្តរជាតិអាចទទួលស្គាល់។

## ៦. អនុសាសន៍សំខាន់ៗ

អនុសាសន៍ខាងក្រោមត្រូវបានធ្វើឡើង ដើម្បីអភិវឌ្ឍដំណាំទីផ្សារក្នុងន័យកត្តាកំណើនមួយសម្រាប់កាត់បន្ថយភាពក្រីក្រក្នុងព្រះរាជាណាចក្រកម្ពុជា:

១. បង្កើតឲ្យបានឆាប់រហ័សនូវស្ថាប័នដោយឡែកមួយ សម្រាប់តាក់តែងឯកសារនាំចេញ និងបោះផ្សាយស្តង់ដារ និងចេញវិញ្ញាបនបត្រ អនាម័យ និងរុក្ខអនាម័យ "ONE STOP SERVICE."

២. បំពាក់បំប៉នអ្នកវិទ្យាសាស្ត្រដែលមាន ឲ្យក្លាយជាអ្នកឯកទេសដំណាំ ដូចជា អ្នកឯកទេសដំឡូងមី គ្រាប់ស្វាយចន្ទី ពោតជាដើម។

៣. បង្កើនល្បឿនការស្រាវជ្រាវ ដោយធ្វើយ៉ាងណាឲ្យលទ្ធផលដែលទទួលបានអាចជួយរួមចំណែកដល់កសិករ ក្នុងការបង្កើនផលិតភាព ផលិតកម្ម ការកែច្នៃផលិតផល និងការធ្វើម៉ាខេធីង។

៤. ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវជួយឧបត្ថម្ភ កសិករក្នុងការដាំដុះដំណាំទីផ្សារ ក្នុងការបង្កើតសហគមន៍ ដែលស្រដៀងគ្នានឹងសហគមន៍ស្រូវ។

៥. ត្រូវជួយឧបត្ថម្ភ កសិករដំណាំទីផ្សារខ្នាតមធ្យម និងធំ តាមរយៈការជួយរកអង្គការ ឬគ្រឹះស្ថានហិរញ្ញវត្ថុផ្តល់ប្រាក់កំចី សម្រាប់ការធ្វើវិនិយោគ និងពង្រីករោងចក្រកែច្នៃ ក្នុងគោលដៅបង្កើនតម្លៃបន្ថែមចំពោះដំណាំកសិកម្ម ក៏ដូចជាបង្កើននិយោជន៍។

## ៧. សេចក្តីសន្និដ្ឋាន

ឆន្ទៈរបស់កសិករក្នុងការដាំដុះមានជានិច្ច ទោះជាមាន ឬគ្មានជំនួយពីរដ្ឋាភិបាល ឬដៃគូរអភិវឌ្ឍ ក៏ដោយ។ ពួកគាត់នឹងបន្តផលិតដំណាំរបស់ពួកគាត់ ដូច្នេះហើយវាជាការចាំបាច់ណាស់ចំពោះ រាជរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ដៃគូរទ្វេភាគី និងដៃគូរអន្តរជាតិ ក្នុងការចូលប្រលូកដើម្បីជួយ បំពេញឆន្ទៈរបស់កសិករ ក្នុងការផលិត ការកែច្នៃ និងការបញ្ជូនទៅឲ្យទីផ្សារ នូវផលិតផលរបស់ពួកគាត់ ឲ្យបានកាន់តែមានប្រសិទ្ធភាព ដោយផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ។

**ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១០**

**ឯកឧត្តមបណ្ឌិត ស៊ិន ម៉េង ស្រ៊ុន**

**ប្រធានអនុក្រុមការងារកសិកម្ម ECOSOCC**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

## REFERENCES


CDRI (2009). Result of 10 Years Research 1999 – 2009, Cambodia

CDRI (no date). Report on White Corn, Cambodia

CDRI (no date). Report on Yellow Corn , Cambodia

Hyatt Abdull Wahab & Al (2009). Achieving Food Security in Cambodia Through Improved Agriculture and Environmental Sustainability, Cambodia

M H Bio – Energy Co LT D (2008). Report on Corporation , Cambodia

Ministry of Agriculture, Forestry, and Fisheries (2009). Annual Report 2008 – 2009 Cambodia

Ministry of Commerce (2007). Cambodia 's Updated Trade Integration Strategy: DTIS 2007 , Cambodia

Ministry of Commerce (1996). Cambodia Business and Investment Handbook, Cambodia

National Institute of Statistics (2008). Statistical Yearbook, Cambodia

National Institute of Statistics (2005). Statistical Yearbook, Cambodia


## INTERVIEWS

Ann Mardi, Owner of Chamcar Undong, Rubber Plantation & Cassava buyer, Kompong Cham

Mr. Hay, Foreman of Cashew nut plantation at Skun, Kompong Cham